លេខ ១២ ចេញផ្សាយថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២

# ព្រឹត្តបត្រព័ត៌មានប្រចាំខែឧសភា ឆ្នាំ២០២២

និយ័តករបរធនបាលកិច្ច
គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. លើកទី៩ អាណត្តិទី១

នៅព្រឹកថ្ងៃអង្គារ ៣កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** លើកទី៩ អាណត្តិទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមរយៈប្រព័ន្ធអនឡាញ។



រូបភាពកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** លើកទី៩ អាណត្តិទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**។

## មាតិកា


- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. លើកទី៩ អាណត្តិទី១ — ទំព័រ ១
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ — ទំព័រ ២
- កិច្ចប្រជុំលើសមិទ្ធផលការងារសម្រេចបានប្រចាំខែមេសា ឆ្នាំ២០២២ និងទិសដៅការងារសម្រាប់ខែបន្ទាប់របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច — ទំព័រ ២
- កិច្ចប្រជុំពិភាក្សាជាមួយក្រុមហ៊ុនព្រេគ្គន កាថេ អ៊ិនវេសម៉ិន ត្រាស (ខេមបូឌា) ម.ក — ទំព័រ ២
- កិច្ចប្រជុំបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង ន.ប.ធ. ស្តីពី "ការត្រៀមរៀបចំគម្រោងថវិកាក្នុងក្របខណ្ឌ ន.ប.ធ." — ទំព័រ ៣
- កិច្ចប្រជុំជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) — ទំព័រ ៣
- ចូលរួមសន្និសីទជាតិស្តីពីទីផ្សារមូលបត្រនៅកម្ពុជាក្រោមប្រធានបទ "មួយទសវត្សនៃការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា និងដំណើរឆ្ពោះទៅមុខ" និងខួប១០ឆ្នាំនៃផ្សារមូលបត្រកម្ពុជា — ទំព័រ ៣
- កិច្ចប្រជុំពិភាក្សាការងារជាមួយសារព័ត៌មានខេមបូណូមីស — ទំព័រ ៤
- កិច្ចប្រជុំពិភាក្សាការងារជាមួយសមាគមសហគ្រិនវ័យក្មេង (YEAC) — ទំព័រ ៤
- កិច្ចប្រជុំពិភាក្សាការងារជាមួយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC) — ទំព័រ ៥
- កិច្ចប្រជុំពិភាក្សាការងារទ្វេភាគីជាមួយសមាគមធុរកិច្ចនៅកម្ពុជា — ទំព័រ ៥
- កិច្ចប្រជុំពិភាក្សាការងារជាមួយសមាគម ID Investors (IDI) — ទំព័រ ៦
- កិច្ចប្រជុំពិភាក្សាការងារជាមួយអាជ្ញាធររូបិយវត្ថុអន្តរជាតិសិង្ហបុរី (MAS) — ទំព័រ ៦
- កិច្ចប្រជុំពិភាក្សាការងារជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (ទទក) — ទំព័រ ៦
- កិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន ខេមបូឌានប្រូយែសស្ទីងសឺវីស (CBS) — ទំព័រ ៧
- កិច្ចប្រជុំពិភាក្សាការងារជាមួយស៊ីអ៊ីអូ ម៉ាស្ទ័រ ក្លឹប — ទំព័រ ៧
- កិច្ចប្រជុំពិភាក្សាការងារជាមួយស្ថានីយទូរទស្សន៍ ភី អ៊ិន អ៊ិន (PNN) — ទំព័រ ៨
- កិច្ចប្រជុំពិភាក្សាការងារជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) — ទំព័រ ៨
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២២ ក្នុងកម្រិតអន្តរនាយកដ្ឋាន — ទំព័រ ៨




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ

នៅព្រឹកថ្ងៃអង្គារ ៣កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ឈី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ។ កិច្ចប្រជុំនេះមានការចូលរួមពីប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋានកិច្ចការទូទៅទាំងអស់។ កិច្ចប្រជុំត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា និងស្មារតីមោះមុតក្នុងការបំពេញការងារតាមផែនការខែបន្ទាប់។



រូបភាពក្នុងកិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅដឹកនាំដោយ ឯកឧត្តមអគ្គនាយករង **ឈី សាគល**

## កិច្ចប្រជុំលើសមិទ្ធផលការងារសម្រេចបានប្រចាំខែមេសា ឆ្នាំ២០២២ និងទិសដៅការងារសម្រាប់ខែបន្ទាប់របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច

នារសៀលថ្ងៃអង្គារ ៣កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ឈី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំលើសមិទ្ធផលការងារសម្រេចបានប្រចាំខែមេសា ឆ្នាំ២០២២ និងទិសដៅការងារសម្រាប់ខែបន្ទាប់របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីមន្ត្រីដឹកនាំការងារនាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចទាំងអស់។ កិច្ចប្រជុំត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុស-ត្រូវខ្ពស់។



រូបភាពក្នុងកិច្ចប្រជុំលើសមិទ្ធផលការងារសម្រេចបានប្រចាំខែមេសា ឆ្នាំ ២០២២ និងទិសដៅការងារសម្រាប់ខែបន្ទាប់របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចដឹកនាំដោយ ឯកឧត្តមអគ្គនាយករង **ឈី សាគល**

## កិច្ចប្រជុំពិភាក្សាជាមួយក្រុមហ៊ុនប្រេ្គន កាថេ អ៊ិនវេសមិន ត្រាស (ខេមបូឌា) ម.ក

នាព្រឹកថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយលោក ហាយ សុវណ្ណា ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងមន្ត្រីជំនាញ បានទទួលជួបប្រជុំពិភាក្សាការងារជាមួយលោក Eric Chu ប្រធានក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំក្រុមហ៊ុន ប្រេ្គន កាថេ អ៊ិនវេសមិន ត្រាស (ខេមបូឌា) ម.ក ដើម្បីពិភាក្សាអំពីការអភិវឌ្ឍ និងកាលានុវត្តភាពវិនិយោគនៅក្នុងវិស័យបរធនបាលកិច្ច ក៏ដូចជាគម្រោងផែនការធ្វើអាជីវកម្មក្នុងវិស័យបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយក ក៏ដូចជាភាគីខាងក្រុមហ៊ុន បានផ្លាស់ប្តូរ និងចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកលើកិច្ចដំណើរការអភិវឌ្ឍ កាលានុវត្តភាព ក្របខណ្ឌគតិយុត្ត ផ្នែកបច្ចេកទេស និងផ្នែក FINTECH ផងដែរ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាពក្នុងកិច្ចប្រជុំពិភាក្សាជាមួយក្រុមហ៊ុនហ្រ្គេន កាថេ អ៊ិនវេសមិន ត្រាស (ខេមបូឌា) ម.ក ដឹកនាំដោយឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**

## កិច្ចប្រជុំបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង ន.ប.ធ. ស្តីពី "ការត្រៀមរៀបចំគម្រោងថវិកាក្នុងក្របខណ្ឌ ន.ប.ធ."

នាព្រឹកថ្ងៃព្រហស្បតិ៍ ១២កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានដឹកនាំកិច្ចប្រជុំបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី "ការត្រៀមរៀបចំគម្រោងថវិកាក្នុងក្របខណ្ឌ **ន.ប.ធ.**" ដោយមានការអញ្ជើញចូលរួមពី លោក កញ្ញា ប្រធាននាយកដ្ឋាន មន្ត្រីដឹកនាំការងារនាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រីជំនាញនាយកដ្ឋានពាក់ព័ន្ធទាំងអស់នៃ **ន.ប.ធ.**។ កិច្ចប្រជុំនេះ ក៏ត្រូវបានបញ្ចូលផងដែរនូវការធ្វើបទបង្ហាញដោយប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ ហើយបានបញ្ចប់ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាពកិច្ចប្រជុំបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី "ការត្រៀមរៀបចំគម្រោងថវិកាក្នុងក្របខណ្ឌ **ន.ប.ធ.**" ដឹកនាំដោយ ឯកឧត្តមអគ្គនាយករង **ណឹ សាគល**

## កិច្ចប្រជុំជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)

នារសៀលថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានចូលរួមកិច្ចប្រជុំជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងដោយមានការចូលរួមពីតំណាងនិយ័តករពាក់ព័ន្ធក្រោមឱវាទរបស់ **អ.ស.ហ.**។




រូបភាពកិច្ចប្រជុំជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដឹកនាំដោយ ឯកឧត្តមអគ្គនាយកនាយក **សុខ ដារ៉ា**

## ចូលរួមសន្និសីទជាតិស្តីពីទីផ្សារមូលបត្រនៅកម្ពុជាក្រោមប្រធានបទ "មួយទសវត្សនៃការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា និងដំណើរឆ្ពោះទៅមុខ" និងខួប១០ឆ្នាំនៃផ្សារមូលបត្រកម្ពុជា

នាព្រឹកថ្ងៃចន្ទ ១រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសនៅក្នុងសន្និសីទជាតិស្តីពីទីផ្សារមូលបត្រនៅកម្ពុជាក្រោមប្រធានបទ "មួយទសវត្សនៃការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា និងដំណើរឆ្ពោះទៅមុខ" និងខួប១០ឆ្នាំនៃផ្សារមូលបត្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។



រូបភាពក្នុងចូលរួមសន្និសីទជាតិស្តីពីទីផ្សារមូលបត្រនៅកម្ពុជាក្រោមប្រធានបទ "មួយទសវត្សនៃការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា និងដំណើរឆ្ពោះទៅមុខ" និងខួប១០ឆ្នាំនៃផ្សារមូលបត្រកម្ពុជា

## កិច្ចប្រជុំពិភាក្សាការងារជាមួយសារព័ត៌មានខេមបូណូមីស

នារសៀលថ្ងៃចន្ទ ១រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយ លោក **ស៊ីន សាយ** នាយកប្រតិបត្តិនៃសារព័ត៌មានខេមបូណូមីស អមដោយសហការី ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) និងសារព័ត៌មានខេមបូណូមីស (Cambonomist) ក្នុងគោលដៅជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។



រូបភាពកិច្ចប្រជុំពិភាក្សាការងារជាមួយសារព័ត៌មានខេមបូណូមីស ដឹកនាំដោយឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**

## កិច្ចប្រជុំពិភាក្សាការងារជាមួយសមាគមសហគ្រិនវ័យក្មេង (YEAC)

នាព្រឹកថ្ងៃអង្គារ ២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយសមាគមសហគ្រិនវ័យក្មេង (YEAC) តំណាងដោយ លោក **ចាន់ វាសនា** អនុប្រធានសមាគម, លោកស្រី **ប៉ោ ជូ** ប្រធានគណៈកម្មការទី១៤ លោក **ប៊ុន សម្បត្តិ** អគ្គលេខាធិការសមាគម និងលោក **ស៊ីម តារា** នាយកប្រតិបត្តិសមាគម ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសមាគមសហគ្រិនវ័យក្មេង (YEAC) ក្នុងគោលដៅជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមរបស់វិនិយោគិន និងធុរកិច្ចជន ក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។



រូបភាពកិច្ចប្រជុំពិភាក្សាការងារជាមួយសមាគមសហគ្រិនវ័យក្មេង (YEAC) ដឹកនាំដោយឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**

## កិច្ចប្រជុំពិភាក្សាការងារជាមួយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC)

នាព្រឹកថ្ងៃអង្គារ ២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយសម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា (FASMEC) ដោយមានការចូលរួមពី លោកឧកញ៉ា **តែ តាំងប៉** ប្រធានក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា អមដោយ លោកឧកញ៉ា **សុខ ដារ៉ា** អនុប្រធានក្រុមប្រឹក្សាភិបាល និងសហការី ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ជាមួយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា ក្នុងគោលដៅជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមរបស់វិនិយោគិន និងធុរកិច្ចជនក្នុងវិស័យបរធន-បាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។




រូបភាពកិច្ចប្រជុំពិភាក្សាការងារជាមួយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC) ដឹកនាំដោយ ឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**

## កិច្ចប្រជុំពិភាក្សាការងារទ្វេភាគីជាមួយសមាគមធុរកិច្ចនៅកម្ពុជា

នាព្រឹកថ្ងៃពុធ ៣រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារទ្វេភាគីជាមួយសមាគមធុរកិច្ចនៅកម្ពុជា ចំនួន ៣ ក្នុងជំនួបផ្សេងគ្នា ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហ-ប្រតិបត្តិការជាមួយនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ក្នុងគោលដៅជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន៖

១.សមាគមក្លឹបអ្នកវិនិយោគកម្ពុជា (CiC) ដែលតំណាងដោយ លោក **ឡៃម ចាន់សំរេច** នាយកគ្រប់គ្រង អមដោយសហការី

២.សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា (HDAC) តំណាងដោយ លោក **ហ៊ុយ វណ្ណា** អគ្គលេខាធិការ អមដោយសហ-ការី និងសមាជិកជាច្រើនរូបរបស់សមាគម

៣. សមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា (CVEA) ដោយមានការចូលរួមពី លោក **ច្រឹក សុខនីម** ប្រធានសមាគម, លោក ពឹង សេរី អនុប្រធានសមាគម, លោកស្រី គ្រេស រចនី ហ្វុង, សមាជិកក្រុមប្រឹក្សាភិបាល អមដោយសហការី។




រូបភាពកិច្ចប្រជុំពិភាក្សាការងារទ្វេភាគីជាមួយសមាគមធុរកិច្ចនៅកម្ពុជា ដឹកនាំដោយ ឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សាការងារជាមួយសមាគម ID Investors (IDI)

នារសៀលថ្ងៃពុធ ៣រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយសមាគម ID Investors (IDI) ដោយមានការចូលរួមពី លោក **ចាប សុភ័គ** នាយកប្រតិបត្តិ, អ្នកនាង **ប៉ាន់ អម្រឹតធីតា** ប្រធានផ្នែកប្រតិបត្តិការ លោក **ជា ស៊ុនសត្យា** ប្រធានផ្នែកធុរកិច្ច និងវិនិយោគ អមដោយសហការី ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសមាគម ID Investors (IDI) ក្នុងគោលដៅជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។



រូបភាពក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយសមាគម ID Investors (IDI) ដឹកនាំដោយ ឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**

## កិច្ចប្រជុំពិភាក្សាការងារជាមួយអាជ្ញាធររូបិយវត្ថុអន្តរជាតិសិង្ហបុរី (MAS)

នាព្រឹកថ្ងៃសុក្រ ៥រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយអាជ្ញាធររូបិយវត្ថុអន្តរជាតិសិង្ហបុរី (MAS) ដោយមានការចូលរួមពីអ្នកនាង KOH Hong Eng ប្រធាននាយកដ្ឋានអន្តរការីផ្សារមូលធន ក្រុមទីIII តំណាងរបស់លោក LIM Tuang Lee នាយកគ្រប់គ្រងទទួលបន្ទុកផ្នែកទីផ្សារមូលធន អមដោយ លោក TEO Kai Xiang អនុប្រធាននាយកដ្ឋាន និងជាប្រធានការិយាល័យទី១ នៃនាយកដ្ឋានអន្តរការីផ្សារមូលធនក្រុមទីIII ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងអាជ្ញាធររូបិយវត្ថុអន្តរជាតិសិង្ហបុរី (MAS) ក្នុងក្របខណ្ឌវិស័យបរធនបាលកិច្ច។



រូបភាពក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយសមាគម ID Investors (IDI) ដឹកនាំដោយ ឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**

## កិច្ចប្រជុំពិភាក្សាការងារជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (ទទក)

នាព្រឹកថ្ងៃសុក្រ ៥រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (**ទទក**) ដោយមានការចូលរួមពីលោកជំទាវ **កុច មារតី**

អគ្គនាយករងនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (**ទទក**) តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ឃឹម វុទ្ធី** អគ្គនាយកនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (**ទទក**) អមដោយ លោក **យ៉េង សីហា** អគ្គនាយករង និង លោក **ប៉ាវ ម៉េងស្រ៊ុន** ប្រធាននាយកដ្ឋានផលិតកម្មវិធី ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (**ទទក**) ក្នុងគោលដៅជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។



រូបភាពក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (ទទក) ដឹកនាំដោយ ឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**

## កិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន ខេមបូឌានប្រូយែសស្ទីងសឺវីស (CBS)

នាព្រឹកថ្ងៃសុក្រ ៥រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន ខេមបូឌានប្រូយែសស្ទីងសឺវីស (CBS) ដោយមានការចូលរួមពី លោក **តែ រតនៈ** អ្នកគ្រប់គ្រងជាន់ខ្ពស់ ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងក្រុមហ៊ុន ខេមបូឌានប្រូយែសស្ទីងសឺវីស (CBS) ក្នុងគោលដៅជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។





រូបភាពក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន ខេមបូឌានប្រូយែសស្ទីងសឺវីស (CBS) ដឹកនាំដោយ ឯកឧត្តមអគ្គនាយករង **នង ពិសិដ្ឋ**

## កិច្ចប្រជុំពិភាក្សាការងារជាមួយស៊ីអ៊ីអូ ម៉ាស្ទ័រ ក្លឹប

នារសៀលថ្ងៃសុក្រ ៥រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយ ស៊ីអ៊ីអូ ម៉ាស្ទ័រ ក្លឹប ដោយមានការចូលរួមពី លោក **ស៊ាន ធនិន** នាយកប្រតិបត្តិ តំណាងលោក **អោម សេងបូរ៉ា** ស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៃស៊ីអ៊ីអូ ម៉ាស្ទ័រ ក្លឹប ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងស៊ីអ៊ីអូ ម៉ាស្ទ័រ ក្លឹប ក្នុងគោលដៅជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។



រូបភាពក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយស៊ីអ៊ីអូ ម៉ាស្ទ័រ ក្លឹប ដឹកនាំដោយ ឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សាការងារជាមួយស្ថានីយទូរទស្សន៍ ភី អុិន អុិន (PNN)

ព្រឹកថ្ងៃចន្ទ ៨រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយ ស្ថានីយទូរទស្សន៍ ភី អុិន អុិន (PNN) ដោយមានការចូលរួមពីលោក **ប៉ែន បូណា** នាយកនិពន្ធ និងជាប្រធានផ្នែកព័ត៌មាន តំណាងរបស់លោកឧកញ៉ា **លី ឆុកឆៃ** អគ្គនាយកនៃស្ថានីយទូរទស្សន៍ ភី អុិន អុិន (PNN) ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការរវាងនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) និងស្ថានីយទូរទស្សន៍ ភី អុិន អុិន (PNN) ក្នុងគោលដៅជំរុញការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។



រូបភាពក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយស្ថានីយទូរទស្សន៍ ភី អុិន អុិន (PNN) ដឹកនាំដោយ ឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**

## កិច្ចប្រជុំពិភាក្សាការងារជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

នាព្រឹកថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង លោក/កញ្ញាប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយ តំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយមានការចូលរួមពីលោកស្រី Benita Ainabe អ្នកជំនាញវិស័យហិរញ្ញវត្ថុជាន់ខ្ពស់ នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងលោក Kosintr Puongsophal អ្នកជំនាញវិស័យហិរញ្ញវត្ថុ នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB), លោក Poullang Doung, មន្ត្រីជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អមដោយសហការី ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការបច្ចេកទេសរវាងនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងធនាគារអភិវឌ្ឍអាស៊ី (ADB) ក្នុងគោលដៅជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។




រូបភាពក្នុងតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដឹកនាំដោយ ឯកឧត្តមអគ្គនាយក **សុខ ដារ៉ា**

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២២ ក្នុងកម្រិតអន្តរនាយកដ្ឋាន

នាព្រឹកថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២២ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ។ កិច្ចប្រជុំនេះមានការចូលរួមពីប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋានប្រធានការិយាល័យ អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។

នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករង បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែឧសភា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះបានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។




រូបភាពក្នុងកិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២២ ក្នុងកម្រិតអន្តរនាយក ដឹកនាំដោយ ឯកឧត្តមអគ្គនាយករង **ឧទ ពិសិដ្ឋ**



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888